KHMER

Commonwealth Ombudsman

# ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាពាក់ព័ន្ធនឹងរឿងរ៉ាវសហព័ន្ធ

ភ្នាក់ងារស៊ើបអង្កេតរឿងរ៉ាវសហព័ន្ធគឺជាបុគ្គលឯករាជ ធ្វើការអង្កេតតាមដានបណ្តឹងនានាប្រឆាំងនឹងក្រសួងរដ្ឋាភិបាលសហព័ន្ធ។

## មុខងាររបស់ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាអាចធ្វើការអង្កេតតាមដានបណ្តឹងទាំងឡាយពាក់ព័ន្ធទៅនឹងទីភ្នាក់ងារភាគច្រើននៃរដ្ឋាភិបាលអូស្ត្រាលី ដោយរួមទាំង Centrelink ការិយាល័យពន្ធដារ ទីភ្នាក់ងារផ្គត់ផ្គង់ចិញ្ចឹមកូន ក្រសួងអន្តោប្រវេសន៍ និង ប្រៃសណីយ៍អូស្ត្រាលីជាដើម។

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ានឹងធ្វើសេចក្តីសំរេចថាតើទង្វើ ឬក៏សេចក្តីសំរេចទាំងពួងដែលគេអះអាងនោះពិតជាខ្វះភាពត្រឹមត្រូវ, មិនសមហេតុផល, មិនយុត្តិធម៌ ឬក៏មានការប្រកាន់រើសអើងដែរឬទេ។ ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាក៏មើលការខុសត្រូវចំពោះការស៊ើបអង្កេតលើការឃឹតឃុំ ឬក៏កង្វះការចាត់សកម្មភាពផ្នែករដ្ឋបាលជាដើម។

យ៉ាងណាមិញ ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាមិនអាចស៊ើបអង្កេតបណ្តឹងតវ៉ាពាក់ព័ន្ធនឹងបុគ្គល ឬក្រុមហ៊ុនឯកជន សេចក្តីសំរេចរបស់តុលាការ សកម្មភាពឬក៏សេចក្តីសំរេចរបស់រដ្ឋ ឬក៏សាលាក្រុង មន្ត្រីរដ្ឋាភិបាល ឬក៏សហគ្រិនអាជីវកម្មមួយចំនួនរបស់រដ្ឋាភិបាលបានឡើយ។

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាជាជនដែលមិនលំអៀង ហើយមានតួនាទីស្វែងរកលទ្ធផលត្រឹមត្រូវ។

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាធ្វើការដើម្បីកែលំអកិច្ចការរដ្ឋបាលសាធារណៈឲ្យមានលក្ខណៈប្រសើរឡើង ដើម្បីទប់រារាំងកុំឲ្យបញ្ហាបែបនេះកើតមានឡើងម្តងហើយម្តងទៀត។

## អំណាចរបស់ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាមានអំណាចធំទូលាយសំរាប់ធ្វើការស៊ើបអង្កេតបណ្តឹងទាំងពួង ដោយរួមទាំងអំណាចចេញបញ្ជាឲ្យភ្នាក់ងារទាំងឡាយប្រគល់ឯកសារ ឬឆ្លើយតបទៅនឹងសំណួរនានា។ បើសិនជាភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ារកឃើញកំហុសនៅក្នុងកិច្ចការរដ្ឋបាល ភ្នាក់ងារនេះអាចស្នើសុំឲ្យទីភ្នាក់ងារទទួលខុសត្រូវនោះ កែតម្រូវកំហុសនោះ ឬដោះស្រាយបញ្ហានោះ។ ឧទាហរណ៍ ភ្នាក់ងារនេះអាចស្នើសុំឲ្យទីភ្នាក់ងារទទួលខុសត្រូវនោះផ្តល់ការពន្យល់ ឬសុំការអភ័យទោស កែតម្រូវសេចក្តីសំរេចចិត្តណាមួយ បោះបង់ចោលបំណុល ឬក៏សងជំងឺចិត្តជាដើម។